ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ១៥ រោច ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃ ៣១ ខែ កក្កដា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ)

នាព្រឹកថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន **គ.ស.ហ** មានរៀបចំកិច្ចប្រជុំអន្តរក្រសួង ដោយមានការវត្តមានចូលរួមពីឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួនពីរ÷

1. *វឌ្ឍនភាពនៃការអនុវត្តកញ្ចប់វិធានការកែទម្រង់ដែលដាក់ចេញដោយ* ***សម្តេចតេជោនាយករដ្ឋមន្ត្រី*** *ក្នុងវេទិការាជរដ្ឋាភិបាល-ឯកជនលើកទី ១៨ និង*
2. *ការរៀបចំក្របខ័ណ្ឌតាមដានសមិទ្ធកម្មសម្រាប់យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ។*

### ១. វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់ជាកញ្ចប់÷

វិធានការកែទម្រង់ជាកញ្ចប់ដែលត្រូវបានដាក់ចេញដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅក្នុងវេទិការាជរដ្ឋាភិបាល-ឯកជនលើកទី ១៨ នាថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩ មានគោលដៅកែលម្អបរិយាកាសវិនិយោគ, និងលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងភាពប្រកួតប្រជែងរបស់កម្ពុជា តាមរយៈការដោះស្រាយនូវបញ្ហាប្រឈមធំៗមួយចំនួនរួមមាន÷ ការកាត់បន្ថយថ្លៃឡជីស្ទីកនិងសេវាកំពុងផែ, ការកាត់បន្ថយថ្លៃអគ្គិសនី, ការកាត់បន្ថយថ្លៃឈប់សម្រាក, ការពង្រឹងសេវាសាធារណៈ និងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ជាដើម ។

គិតត្រឹមឆមាស ទី ១ ឆ្នាំ ២០១៩, ក្រសួង-ស្ថាប័ន ទទួលបន្ទុកបានអនុវត្តវិធានការទាំងនោះ ដោយសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ។ វិធានការភាគច្រើនត្រូវបានអនុវត្ត និងបន្តតាមដាន ទន្ទឹមនេះក៏មានវិធានការមួយចំនួនតូចតម្រូវឱ្យមានការបង្កើនល្បឿន ដើម្បីអាចសម្រេចបានតាមពេលវេលាដែលបានគ្រោងទុក ។ បន្ថែមលើនេះ, អង្គប្រជុំ បានលើកទឹកចិត្ត និងជំរុញឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចនូវវិធានការដែលពុំទាន់សម្រេចបានទាំងស្រុង ដោយធ្វើយ៉ាងណាឱ្យបានបញ្ចប់តាមការគ្រោងទុកត្រឹមដំណាច់ឆ្នាំ ២០១៩ នេះ ។

### ២. ក្របខ័ណ្ឌតាមដានសមិទ្ធកម្មសម្រាប់យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤÷

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ

ចតុកោណ-ដំណាក់កាលទី ៤ តាមរយៈការកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicators - KPIs) ។ ក្របខ័ណ្ឌតាមដានសមិទ្ធកម្ម សម្រាប់យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ គឺជាគំនិតផ្តួចផ្តើមថ្មីមួយក្នុងការរៀបចំយន្តការ និងឧបករណ៍តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ហើយដែលលទ្ធផលនេះនឹងត្រូវប្រើប្រាស់ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់រាជរដ្ឋាភិបាល សំដៅគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យឆ្នាំ ២០៣០ ។ ការកំណត់ និងជ្រើសរើសនូវសូចនាករទាំងនោះមានការពិភាក្សាពិគ្រោះយោបល់ និងគិតគូរយ៉ាងលម្អិតទៅលើឯកសារពាក់ព័ន្ធសំខាន់ៗ របស់រាជរដ្ឋាភិបាល រួមមាន ***"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ (NSDP)" និង "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG)"*** ជាដើម ។ ជាងនេះទៅទៀត, ក្របខ័ណ្ឌតាមដានសមិទ្ធកម្មនេះ ក៏បានដាក់ជូនពិគ្រោះយោបល់កម្រិតបច្ចេកទេសជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយទទួលបានធាតុចូល និងមតិកែលម្អជាច្រើនផងដែរ មុននឹងដាក់ឆ្លងកិច្ចប្រជុំពិភាក្សាក្នុងថ្ងៃនេះ ។ ជារួម, អង្គប្រជុំបានសម្តែងនូវការគាំទ្រចំពោះគំនិតផ្តួចផ្តើមក្នុងការដាក់ចេញនូវក្របខណ្ឌតាមដាននេះ ហើយប្តេជ្ញាបន្តកិច្ចសហការក្នុងការកែលម្អសូចនាករសមិទ្ធកម្មគន្លឹះទាំងនោះ ដើម្បីឱ្យក្របខណ្ឌតាមដានវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានភាពជឿទុកចិត្តខ្ពស់ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ស.ហ** ដែលបាន ខិតខំនិងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកិច្ចការដ៏មានសារៈសំខាន់ទាំងនេះ នឹងបានស្នើឱ្យគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តកិច្ចសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។